ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការរំលាយកិច្ចសន្យា


រៀបចំដោយ៖
ក្រសួងយុត្តិធម៌វិទ្យាស្ថានស្រាវជ្រាវទូទៅអំពី
កិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្រ្តាចារ្យ៖ UMEMOTO Yumi



ចែករំលែកដោយ៖ មេធាវីតម្រាច្បាប់
www.legalcodelawfirm.com
www.facebook.com/legalcodelawfirm
App Store & Play Store : LEGAL CODE LIBRARY (បណ្ណាល័យតម្រាច្បាប់)

# ការរំលាយកិច្ចសន្យា

ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ UMEMOTO Yumi

# មាតិកានៃបទឧទ្ទេសនាម



1. អត្ថន័យនៃការរំលាយ (តើការរំលាយកិច្ចសន្យាជាអ្វី? )
2. លក្ខខណ្ឌនៃការរំលាយ (តើគួរធ្វើយ៉ាងណាទើបអាចរំលាយកិច្ចសន្យាបាន?)
3. អានុភាពនៃការរំលាយ (នៅពេលរំលាយកិច្ចសន្យា តើទំនាក់ទំនងសិទ្ធិរវាងភាគី និង តតិយជននឹងក្លាយជាយ៉ាងណា?)
4. អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា
5. ការរំលាយដែលកំណត់ក្នុងកិច្ចសន្យា · ការរំលាយដោយការព្រមព្រៀង
6. សំនួរ និង ចម្លើយ

# 1. ការរំលាយកិច្ចសន្យា គឺជា



- នៅថ្ងៃទី១ ខែសីហា Y បានចុះកិច្ចសន្យាទិញអង្ករពី X ចំនួន ១០តោន ក្នុងតម្លៃ ៥០០០$។ ហើយតម្រូវឲ្យ X ដឹកអង្ករទៅឃ្លាំងរបស់ Y នៅថ្ងៃទី១០ ខែសីហា។
- ទោះបីជាថ្ងៃទី១០ ខែសីហា បានកន្លងផុតក៏ដោយ តែ X នៅតែមិនដឹកអង្ករមកឡើយ។



# 1. ការរំលាយកិច្ចសន្យា គឺជា



- ប្រសិនបើអ្នកលក់ X មិនអនុវត្តកាតព្វកិច្ច អ្នកទិញ Y អាចជ្រើសរើសមធ្យោបាយដូចខាងក្រោម (CC390) ៖

1. អនុវត្តដោយបង្ខំ (CC396)

   អាចទាមទារឲ្យអនុវត្តដោយបង្ខំ តាមបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

2. ទាមទារសំណងការខូចខាត (CC398)

   អាចទាមទារសំណងការខូចខាត ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចដោយមានកំហុស។

3. រំលាយកិច្ចសន្យា (CC407)

   នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ក្នុងករណីភាគីម្ខាងបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបានភ្លាមៗ។

→ ភាគីអាចជ្រើសរើសយកមធ្យោបាយសង្គ្រោះច្រើនយ៉ាង ក្នុងទំហំដែលមិនមានភាពផ្ទុយគ្នា (CC395) ។

# 1. ការរំលាយកិច្ចសន្យា គឺជា



- អ្នកទិញ Y អាចរំលាយកិច្ចសន្យា ហើយរួចផុតពីករណីយកិច្ចបង់ប្រាក់ថ្លៃទិញ។

1. ក្នុងករណីមិនទាន់បង់ថ្លៃទិញ

→ បដិសេធការអនុវត្តកាតព្វកិច្ច

ក្នុងករណីដែលអ្នកលក់ X ទាមទារឲ្យបង់ប្រាក់ អ្នកទិញ Y អាចរំលាយកិច្ចសន្យា ហើយបដិសេធមិនបង់ថ្លៃទិញបាន។

2. ក្នុងករណីបង់ថ្លៃទិញហើយ

→ ទាមទារឲ្យធ្វើបដិទាន

អ្នកទិញ Y អាចរំលាយកិច្ចសន្យា ហើយទាមទារចំពោះអ្នកលក់ X ឲ្យប្រគល់ប្រាក់ថ្លៃទិញដែលបានបង់ហើយមកវិញ។

# ភាពខុសគ្នារវាងការរំលាយ និង ការលុបចោល



- ទាំងការរំលាយ និង ការលុបចោល មានអានុភាពធ្វើឲ្យភាគីនៃកិច្ចសន្យារួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា (CC358,411) ។
- ការលុបចោល គឺជាការទទួលស្គាល់ថា ដំណើរការនៃការធ្វើកិច្ចសន្យាមានបញ្ហាដោយសារស្ថានភាពនៅពេលបង្កើតកិច្ចសន្យា។
- ការរំលាយ គឺជាការទទួលស្គាល់ភាពត្រឹមត្រូវចំពោះការឲ្យភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា ដោយសារការផ្លាស់ប្តូរស្ថានភាពក្រោយពេលបង្កើតកិច្ចសន្យា ដូចជាភាគីម្ខាងទៀតបំពានកិច្ចសន្យាជាដើម ដែលមិនមែនជាបញ្ហាដែលកើតឡើងនៅពេលបង្កើតកិច្ចសន្យានោះទេ។

# 2. លក្ខខណ្ឌនៃការរំលាយ



1. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (CC407, 408(1))
   i. អនុវត្តយឺតយ៉ាវ + ការដាស់តឿន
   ii. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា
   iii. អលទ្ធភាពក្នុងការអនុវត្ត
   iv. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា
   v. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផ្សេងទៀត

2. ការបង្ហាញឆន្ទៈរំលាយ (CC409)

- ចំពោះលក្ខខណ្ឌនៃការរំលាយមិនតម្រូវឲ្យមានកំហុសរបស់កូនបំណុលនោះទេ (CC408(2)) ។
  យោង. ចំពោះសំណងការខូចខាត តម្រូវឲ្យមានកំហុសរបស់កូនបំណុល (CC398(1)) ។

# 2.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ



ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (CC408)

- និយមន័យ

  ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។

- ប្រភេទនៃការបំពាន

  បើមានករណីក្នុងចំណុច ក~ឃ កថាខណ្ឌទី១ នៃមាត្រា ៤០៨ ត្រូវចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

- ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផ្សេងទៀត

  ទោះបីជាមិនត្រូវនឹងចំណុច ក~ឃ កថាខណ្ឌទី១ នៃមាត្រា ៤០៨ ក៏ដោយ ក៏អាចមានស្ថានភាពខ្លះ ដែលតុលាការអាចវិនិច្ឆ័យថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផងដែរ។

- នៅថ្ងៃទី១ ខែសីហា Y បានចុះកិច្ចសន្យាទិញអង្ករពី X ចំនួន ១០តោន ក្នុងតម្លៃ ៥០០០$។ ហើយតម្រូវឲ្យ X ដឹកអង្ករទៅឃ្លាំងរបស់ Y នៅថ្ងៃទី១០ ខែសីហា។
- នៅថ្ងៃទី៥ ខែសីហា Y បានបង់ប្រាក់ថ្លៃទិញ។
- ថ្ងៃទី១០ ខែសីហាបានកន្លងផុតហើយ តែ X នៅតែមិនទាន់ដឹកអង្ករមក។
- នៅថ្ងៃទី១៥ ខែសីហា  Y បានទាមទារឲ្យ X ដឹកអង្ករមកត្រឹមថ្ងៃទី៣១ ខែសីហា។
- ថ្ងៃទី៣១ ខែសីហាបានកន្លងផុតហើយ តែ X នៅតែមិនទាន់ដឹកអង្ករមក។



# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



1. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (CC408(1))
   i. អនុវត្តយឺតយ៉ាវ + ការដាស់តឿន

      ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឲ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។

   ii. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា
   iii. អលទ្ធភាពក្នុងការអនុវត្ត
   iv. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា
   v. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផ្សេងទៀត
2. ការបង្ហាញឆន្ទៈរំលាយ (CC409)

# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



"ភាគីម្ខាងទៀតដែលមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់"

- លក្ខខណ្ឌទី១ មានការកំណត់ពេលអនុវត្ត
- លក្ខខណ្ឌទី២ ពេលកំណត់ត្រូវអនុវត្តបានកន្លងផុត



បើមិនបានកំណត់ពេលអនុវត្តថា ថ្ងៃណាច្បាស់លាស់ទេ តើត្រូវធ្វើយ៉ាងណា?

## 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



ការយឺតយ៉ាវក្នុងការអនុវត្ត (CC391)

កូនបំណុលត្រូវចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ច នៅពេលដែលបានកំណត់ដូចខាងក្រោម ៖

1. ករណីដែលមានពេលកំណត់ពិតប្រាកដ
   → ថ្ងៃកំណត់នោះបានមកដល់
2. ករណីដែលមានពេលកំណត់មិនពិតប្រាកដ (ថ្ងៃដែលត្រូវតែមកដល់ តែមិនដឹងថាមកដល់នៅពេលណា )
   → នៅពេលដែលកូនបំណុលដឹងថាដល់ពេលកំណត់ហើយ

   ឧទា. X សន្យាចំពោះ Y ថានឹងសងប្រាក់វិញ នៅពេលដែលឪពុកទទួលមរណភាព។

   → នៅពេលដែល X ដឹងថា ឪពុកទទួលមរណភាព ហើយមិនព្រមសងប្រាក់ទេ នោះវានឹងក្លាយជាការយឺតយ៉ាវក្នុងការអនុវត្ត។
3. នៅពេលដែលមិនបានកំណត់ពេល
   → នៅពេលដែលកូនបំណុលទទួលការទាមទារឱ្យអនុវត្ត

## 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)

“នៅពេលដែលភាគីម្ខាងមិនអនុវត្តកាតព្វកិច្ចក្នុងពេលកំណត់ដាស់តឿន ទោះបីជាភាគីម្ខាងទៀតបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យក៏ដោយ ”

<u>លក្ខខណ្ឌទី៣ ការដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ</u>



តើអំឡុងពេលសមរម្យមានរយៈពេលប៉ុន្មាន?
ក្នុងករណីដាស់តឿនដោយមិនបានកំណត់ពេលសមរម្យ តើត្រូវធ្វើយ៉ាងម៉េច?

## 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



- អំឡុងពេលសមរម្យ

  នេះមិនមែនជាការគណនាអំឡុងពេលចាំបាច់ដើម្បីរៀបចំក្នុងការអនុវត្តពីពេលដែលបានទទួលការដាស់តឿន រហូតដល់ការអនុវត្តស្ថាពរនោះទេ ប៉ុន្តែ ជាការគណនាអំឡុងពេលដោយសន្និដ្ឋានថា ការរៀបចំដើម្បីអនុវត្តមួយភាគធំបានធ្វើរួចរាល់ហើយ។

- ក្នុងករណីជូនដំណឹងដោយមិនបានកំណត់អំឡុងពេលសមរម្យ

  ទោះបីជាមានការដាស់តឿនដោយកំណត់អំឡុងពេលមិនសមរម្យ ឬ មិនបានកំណត់អំឡុងពេលក៏ដោយ ក៏ការរំលាយចោលអាចធ្វើបានដែរ នៅពេលដែលអំឡុងពេលសមរម្យបានកន្លងផុត ចាប់ពីពេលបានដាស់តឿននោះ។

  → ទោះបីជាគ្មានការដាស់តឿនក៏ដោយ ក៏កូនបំណុលត្រូវអនុវត្តនៅពេលកំណត់អនុវត្តមកដល់ដែរ។ បើទោះបីជាក្នុងករណីដែលការអនុវត្តយឺតយ៉ាវក៏ដោយ ក៏ជាទូទៅ កូនបំណុលគួរតែបានរៀបចំដើម្បីអនុវត្តហើយមួយភាគធំដែរ ហេតុនេះយើងគ្រាន់តែផ្តល់អំឡុងពេលសមរម្យ ក្រោយពេលដាស់តឿនជាការគ្រប់គ្រាន់។

# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



"នៅពេលដែលភាគីម្ខាងមិនបានអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលដាស់តឿន ទោះបីជាភាគីម្ខាងទៀតបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យក៏ដោយ"

- លក្ខខណ្ឌទី៣ ការដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ

ឬ

- លក្ខខណ្ឌទី៣-១ ការបានដាស់តឿន និង
- លក្ខខណ្ឌទី៣-២ ការកន្លងផុតនៃអំឡុងពេលសមរម្យ ក្រោយពេលដាស់តឿន



តើចាំបាច់ត្រូវអះអាង・បញ្ជាក់អំពីការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ឬទេ?

# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



ម្ចាស់បំណុលមិនចាំបាច់អះអាងអំពីការមិនអនុវត្តរបស់កូនបំណុល នៅពេលកំណត់ និង អំឡុងពេលដាស់តឿននោះទេ។

- ការបញ្ជាក់អំពី "ការមិនអនុវត្ត" ដែលជាអង្គហេតុអកម្ម គឺ លំបាក។
- ការសងជាហេតុនាំឲ្យរលត់កាតព្វកិច្ច ហើយជាការបដិសេធចំពោះការទាមទារឲ្យអនុវត្តរបស់ម្ចាស់បំណុល (តវ៉ា) ។ យោង.CC433

→ គប្បីឲ្យ កូនបំណុលធ្វើការតវ៉ា ដោយអះអាង · បញ្ជាក់អំពី "ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន"។

# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



- លក្ខខណ្ឌទី៤ ការអនុវត្ត ឬ សំណើផ្តល់ការសងកាតព្វកិច្ចរបស់ខ្លួន

ចំណុចនេះ មិនមានកំណត់ក្នុងមាត្រានោះទេ ប៉ុន្តែ នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ដើម្បីអាចចាត់ទុកថាភាគីម្ខាងអនុវត្តយឺតយ៉ាវ ដោយ「បំពានកិច្ចសន្យាធ្ងន់ធ្ងរ」 ភាគីម្ខាងទៀតត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន (ឬ ស្នើផ្តល់ការសង) ជាមុនសិន។

## 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តឃើញយ៉ាង+ការជាស់តឿន)



កិច្ចសន្យាលក់ទិញ

- អ្នកលក់អាចប្រកែកមិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុបាន រហូតដល់ពេលអ្នកទិញបានផ្តល់ការសង (CC551(1)) ។
- អ្នកទិញអាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់ការសងចំពោះកាតព្វកិច្ចរបស់ខ្លួន (CC558(1)) ។

→ ភាគីមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នាទៅវិញទៅមក ហេតុនេះ ភាគីម្ខាងអាចបដិសេធការអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន រហូតដល់ពេលភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ច។

→ ប្រសិនបើ ភាគីម្ខាងអនុវត្ត ឬ ស្នើសុំសងកាតព្វកិច្ចរបស់ខ្លួន ភាគីម្ខាងទៀតត្រូវទទួលខុសត្រូវអនុវត្តកាតព្វកិច្ច។

យោង. ការព្រមព្រៀងអនុវត្តជាមុន (CC551(1)វាក្យខណ្ឌ 2, CC558(1) វាក្យខណ្ឌ 2 )

# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ+ការដាស់តឿន)



- សំណើផ្តល់ការសង (CC453)

"ការដែលកូនបំណុលបានរៀបចំចប់សព្វគ្រប់នូវតាវកាលិកសម្រាប់ការសង និង ទាមទារឲ្យម្ចាស់បំណុលទទួលការសងនោះ"

ឧទា.

- នៅក្នុងកិច្ចសន្យាលក់ទិញឡានមួយទឹក អ្នកលក់ (កូនបំណុល) បានប្រាប់ថ្ងៃដែលត្រូវប្រគល់ដល់អ្នកទិញ (ម្ចាស់បំណុល) ហើយបានត្រៀមឡាននោះនៅផ្ទះរបស់ខ្លួន។
- នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ កូនបំណុលបានយកប្រាក់ទៅដល់ផ្ទះរបស់ម្ចាស់បំណុល។

យោង. ទីកន្លែងដែលត្រូវសង (CC445)

- កាតព្វកិច្ចប្រគល់វត្ថុជាក់លាក់ : កន្លែងដែលវត្ថុនោះបានស្ថិតនៅ នៅពេលសិទ្ធិលើបំណុលកើតឡើង
- កាតព្វកិច្ចផ្សេងទៀត : លំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល

# 2.1.1 ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (អនុវត្តយឺតយ៉ាវ + ការដាស់តឿន)



<លក្ខខណ្ឌ>

1. ការកំណត់ពេលអនុវត្ត
2. ការកន្លងផុតនៃពេលកំណត់អនុវត្ត
3. បានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ

   ឬ

   អំឡុងពេលសមរម្យបានកន្លងផុត ក្រោយពេលដាស់តឿន
4. បានអនុវត្ត ឬ ស្នើផ្តល់ការសងកាតព្វកិច្ចរបស់ខ្លួន

# 2.1.2 ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ការអនុវត្តយឺតយ៉ាវចំពោះសកម្មភាពមានកំណត់ពេលវេលា)

1.ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (CC408(1))

i. អនុវត្តយឺតយ៉ាវ + ការដាស់តឿន

ii. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា

ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់ (CC408(1-ខ)) ។

iii. អលទ្ធភាពក្នុងការអនុវត្ត

iv. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា

v. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផ្សេងទៀត

2.ការបង្ហាញឆន្ទៈរំលាយ (CC409)

## 2.1.2 ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ការអនុវត្តយឺតយ៉ាវចំពោះសកម្មភាពមានកំណត់ពេលវេលា)

"ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់"

→ ចំពោះសកម្មភាពដែលមានកំណត់ពេលបែបនេះ ភាគីអាចរំលាយកិច្ចសន្យាភ្លាមៗដោយ<u>មិនដាស់តឿន</u>

ឧទា. ភាគីបានកុម្មង់នំខេកសម្រាប់ពិធីរៀបការ ប៉ុន្តែ មិនអាចប្រគល់ទាន់នៅថ្ងៃរៀបការ។

→ ក្រោយពិធីរៀបការកន្លងផុត ទោះបីជាអនុវត្តក៏ដោយ ក៏គ្មានន័យដែរ។



## 2.1.2 ការបំពានកិច្ចសន្យាផ្ទាល់ខ្លួន (ការអនុវត្តយឺតយ៉ាវចំពោះសកម្មភាពមានកំណត់ពេលវេលា)

<លក្ខខណ្ឌ>

1. ការកំណត់ពេលអនុវត្ត
2. ការកន្លងផុតនៃពេលកំណត់អនុវត្ត
3. គោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់ (សកម្មភាពដែលមានកំណត់ពេលវេលា)
4. បានអនុវត្ត ឬ ស្នើផ្ដល់ការសងកាតព្វកិច្ចរបស់ខ្លួន

※ មិនចាំបាច់ដាស់តឿន

# 2.1.3 ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (អលទ្ធភាពក្នុងការអនុវត្ត)

1. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (CC408(1))
   i. អនុវត្តយឺតយ៉ាវ + ការដាស់តឿន
   ii. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា
   iii. អលទ្ធភាពក្នុងការអនុវត្ត
   ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ (CC408(1-គ))
   iv. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា
   v. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផ្សេងទៀត
2. ការបង្ហាញឆន្ទៈរំលាយ (CC409)

- នៅថ្ងៃទី១ ខែសីហា Y បានចុះកិច្ចសន្យាទិញថូបុរាណពី X ក្នុងតម្លៃ ៥០០០$។ ហើយកំណត់ឱ្យ X យកថូនោះមកដាក់ក្នុងឃ្លាំងរបស់ Y នៅថ្ងៃទី១០ ខែសីហា ។
- នៅថ្ងៃទី៨ ខែសីហា កប៉ាល់ដែលដឹកថូនោះ បានលិចបាត់។
- នៅថ្ងៃទី១០ ខែសីហា Y បានយកប្រាក់ថ្លៃទិញទៅ ហើយទាមទារឲ្យ X ប្រគល់ថូ។



# 2.1.3 ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (អលទ្ធភាពក្នុងការអនុវត្ត)



"នៅពេលដែលមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បង"

<លក្ខខណ្ឌ>

អលទ្ធភាពក្នុងការអនុវត្ត (CC392)

→ការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព តាមស្ថានភាពរូបធាតុ · សង្គម · សេដ្ឋកិច្ច

※ នៅមុនថ្ងៃអនុវត្ត បើសិនជាច្បាស់ថា នៅថ្ងៃអនុវត្តមិនអាចអនុវត្តកាតព្វកិច្ចបាន នោះអលទ្ធភាពក្នុងការអនុវត្តកើតមានឡើងនៅចំណុចពេលនោះ។

※មិនចាំបាច់ត្រូវផុតអំឡុងពេលអនុវត្ត និង មិនចាំបាច់ដាស់តឿនឡើយ។

# 2.1.3 ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (អលទ្ធភាពក្នុងការអនុវត្ត)



ឧទា. ការលក់ទិញថូបុរាណ

- ថូនោះបានបែកខ្ទេច។

→ អលទ្ធភាពតាមរូបធាតុ

- ចោរបានលួចយកថូនោះ។

→ អលទ្ធភាពតាមសង្គម

បើមើលទៅ នៅពេលអនាគតអាចចាប់ចោរនោះបាន ហើយលទ្ធភាពដែលអាចយកថូមកវិញមិនមែនសូន្យនោះទេ ប៉ុន្តែ តាមទស្សនៈសង្គមទូទៅ យើងអាចយល់ថា ជាអលទ្ធភាពក្នុងការអនុវត្ត។

- កប៉ាល់ដឹកថូនោះបានលិចចូលក្នុងបាតសមុទ្រ។

→ អលទ្ធភាពតាមសេដ្ឋកិច្ច

បើមើលតាមលក្ខណៈរូបធាតុ និង សង្គម គឺមានលទ្ធភាពក្នុងការស្រង់កប៉ាល់ បើបានដឹងកន្លែងដែលលិចនោះ ប៉ុន្តែ បើតាមទស្សនៈសេដ្ឋកិច្ច ត្រូវចំណាយសោហ៊ុយយ៉ាងច្រើន ដូចនេះ យើងអាចយល់ថា ជាអលទ្ធភាពក្នុងការអនុវត្ត ។

# 2.1.4 ការបាត់បង់នូវទំនុកចិត្តរវាងគ្នា



1.ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ (CC408(1))

i. អនុវត្តយឺតយ៉ាវ + ការដាស់តឿន

ii. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា

iii. អលទ្ធភាពក្នុងការអនុវត្ត

iv. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា

ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឲ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន (CC408(1-ឃ))។

v. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផ្សេងទៀត

2.ការបង្ហាញឆន្ទៈរំលាយ (CC409)

## 2.1.4 ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ការបាត់បង់នូវទំនុកចិត្តរវាងគ្នា)



"ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឲ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន"

<លក្ខខណ្ឌ>

ការបាត់បង់ទំនុកចិត្ត ដោយសារការបំពានកិច្ចសន្យាហួសហេតុ

ឧទា. Y បានចុះកិច្ចសន្យាផ្គត់ផ្គង់គ្រឿងបន្លាស់ម៉ូតូជាទៀងទាត់ជាមួយ X ។ X តែងតែដឹកគ្រឿងបន្លាស់មកឲ្យយឺតពេល ហើយធ្វើឲ្យការផលិតម៉ូតូរបស់ Y មានការយឺតយ៉ាវ។



1. ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (CC408(1))
   i. ការយឺតយ៉ាវក្នុងការអនុវត្ត + ការដាស់តឿន
   ii. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា
   iii. អលទ្ធភាពក្នុងការអនុវត្ត
   iv. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា
   v. ការបំពានកិច្ចសន្យាធ្ងន់ធ្ងរផ្សេងទៀត
2. **ការបង្ហាញឆន្ទៈរំលាយ (CC409)**

# 2.2 ការបង្ហាញឆន្ទៈរំលាយ



វិធីអនុវត្តសិទ្ធិរំលាយ(CC409(1))

"ភាគីម្ខាងដែលមានសិទ្ធិរំលាយ  អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។"

<លក្ខខណ្ឌ>

ការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀត

# 2.2 ការបង្ហាញឆន្ទៈរំលាយ

តើការបង្ហាញឆន្ទៈរំលាយ ត្រូវតែធ្វើតាមផ្លូវតុលាការ ឬយ៉ាងណា?



# 2.2 ការបង្ហាញឆន្ទៈរំលាយ



CC409(1)

“ការបង្ហាញឆន្ទៈរំលាយអាចធ្វើឡើង<u>ក្រៅតុលាការ</u>បាន។”

- មិនចាំបាច់ត្រូវធ្វើតាមផ្លូវតុលាការទេ។
- ការបង្ហាញឆន្ទៈធ្វើឡើងក្រៅតុលាការក៏បាន។

ការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀត ធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ជាលិខិតក៏បាន ជាអ៊ីម៉ែលក៏បាន។

→ វិវាទអាចដោះស្រាយដោយផ្អែកតាមការរំលាយនៅក្រៅតុលាការ ប្រសិនបើគ្មានបំណងថានឹងមានវិវាទជាមួយភាគីម្ខាងទៀតទេ ។

ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈរំលាយ បានទៅដល់ភាគីម្ខាងទៀត(CC310(2))

ឧទា.

- ថ្ងៃទី០១ ខែសីហា Y បានចុះកិច្ចសន្យាទិញអង្ករ ១០តោន ក្នុងតម្លៃ៥០០០$ ពី X ។ ហើយតម្រូវឲ្យ X ដឹកអង្ករទៅឃ្លាំងរបស់ Y នៅថ្ងៃទី១០ ខែសីហា។
- ថ្ងៃទី០៥ ខែសីហា Y បានបង់ប្រាក់ថ្លៃទិញ។
- ទោះបីជាផុតថ្ងៃទី១០ ខែសីហាក៏ដោយ ក៏ X នៅតែមិនទាន់យកអង្ករមកឲ្យ Y ដែរ។
- ថ្ងៃទី១៥ ខែសីហា Y បានទាមទារឲ្យ X ដឹកអង្ករមក ឲ្យបានត្រឹមថ្ងៃទី៣១ ខែសីហា។
- ទោះបីជាផុតថ្ងៃទី៣១ ខែសីហាក៏ដោយ ក៏ X នៅតែមិនទាន់យកអង្ករមកឲ្យ Y ដែរ។
- ថ្ងៃទី០១ ខែកញ្ញា Y បានសរសេរសំបុត្រថា "រំលាយកិច្ចសន្យា" ហើយសំបុត្រនោះបានទៅដល់ប្រអប់សំបុត្រផ្ទះរបស់ X ។
- ថ្ងៃទី០៥ ខែកញ្ញា X បានឃើញសំបុត្ររបស់ Y ពីក្នុងប្រអប់សំបុត្រ និងបានអានខ្លឹមសារក្នុងសំបុត្រនោះ។



- តើការបង្ហាញឆន្ទៈរំលាយបានមកដល់ X គិតចាប់ពីពេលណា?
  - ថ្ងៃទី០១ ខែកញ្ញា Y បានសរសេរថា "រំលាយកិច្ចសន្យា" រួចដាក់ចូលក្នុងប្រអប់សំបុត្រ។
  - ថ្ងៃទី០៥ ខែកញ្ញា X បានឃើញសំបុត្ររបស់ Y ពីក្នុងប្រអប់សំបុត្រ និងបានអានខ្លឹមសារក្នុងសំបុត្រនោះ។

→ការមកដល់ គឺជាការទៅដល់ក្នុងបរិវេណដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី។

→ពេលដែលសំបុត្របានទៅដល់ប្រអប់សំបុត្រផ្ទះរបស់ភាគីម្ខាងទៀត ទោះបីជាភាគីម្ខាងទៀតមិនចាប់អារម្មណ៍នឹងសំបុត្រនោះក៏ដោយ ក៏យើងអាចយល់ថា សំបុត្រនោះបានទៅដល់ភាគីម្ខាងទៀតដែរ។

→អានុភាពនៃការរំលាយ កើតឡើងនៅពេលដែលសំបុត្រនោះបានដាក់ចូលក្នុងប្រអប់សំបុត្រផ្ទះរបស់ X នៅថ្ងៃទី០១ ខែកញ្ញា។

# 2.2 ការបញ្ចាញឆន្ទៈរំលាយ



- ការបង្ហាញឆន្ទៈរំលាយមិនអាចដកវិញបានទេ (CC409(2))

→ បើសិនជាទទួលស្គាល់ការដក នោះកិច្ចសន្យាដែលបានរំលាយម្តងហើយនឹងមានអានុភាពឡើងវិញ ហើយភាពច្របូកច្របល់នឹងកើតមានឡើង។

- អាចដាក់លក្ខខណ្ឌបង្អង់ (CC409(3))

ឧទា.

- ថ្ងៃទី១៥ ខែសីហា Y បានយកសំបុត្រដែលបានសរសេរថា " បើមិនដឹកអង្ករត្រឹមថ្ងៃទី៣១ ខែសីហាទេ នឹងរំលាយកិច្ចសន្យា" ដាក់ក្នុងប្រអប់សំបុត្រផ្ទះរបស់ X ។
- ថ្ងៃទី១៦ ខែសីហា X បានអានសំបុត្រនោះ។
- ផុតថ្ងៃទី៣១ ខែសីហា X មិនទាន់ដឹកអង្ករមកឲ្យ។

→ អានុភាពនៃការរំលាយកើតមានឡើងនៅថ្ងៃទី៣១ ខែសីហា បានកន្លងផុត ។

## 2.2 ការបង្ហាញឆន្ទៈរំលាយ



- ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយបុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬ ដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ (CC410)
  - →ប្រសិនបើមានបុគ្គលណាមួយក្នុងចំណោមភាគីច្រើននាក់នៃកិច្ចសន្យារំលាយកិច្ចសន្យា ហើយកិច្ចសន្យានៅតែបន្តអត្ថិភាពចំពោះបុគ្គលដទៃទៀត នោះទំនាក់ទំនងសិទ្ធិនៅក្នុងកិច្ចសន្យាកាន់តែមានភាពស្មុគស្មាញ។
  - →ការបង្ហាញឆន្ទៈរំលាយ ត្រូវធ្វើឡើងដោយភាគីទាំងអស់ ឬ ធ្វើឡើងចំពោះភាគីទាំងអស់។

# 2.2 ការបង្ហាញឆន្ទៈរំលាយ



ឧទា.

- ថ្ងៃទី០១ ខែសីហា X បានលក់ដី A ទៅឲ្យ W ・Y・ Z និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ្យពួកគេទាំង៣។ ប៉ុន្តែ ទោះបីជា X បានដាស់តឿនក៏ដោយ ក៏ W ・Y・ Z មិនបានប្រគល់ប្រាក់គ្រប់ចំនួនឲ្យមក X ដែរ។
- ថ្ងៃទី២០ ខែកញ្ញា X បានផ្ញើអ៊ីម៉ែលដែលមានខ្លឹមសារសុំរំលាយកិច្ចសន្យាលក់ទិញឲ្យទៅ W។
- ថ្ងៃទី២៨ ខែកញ្ញា X បានខលទៅ Y ប្រាប់ពីការរំលាយកិច្ចសន្យាលក់ទិញ។
- ថ្ងៃទី០១ ខែតុលា X បានដាក់លិខិតជូនដំណឹងអំពីការរំលាយក្នុងប្រអប់សំបុត្រនៅផ្ទះរបស់ Z។

→ការបង្ហាញឆន្ទៈមិនចាំបាច់ត្រូវធ្វើក្នុងពេលព្រមគ្នានោះទេ គឺអាចធ្វើនៅពេលបន្តបន្ទាប់បាន ប៉ុន្តែអានុភាពនៃការរំលាយកិច្ចសន្យានឹងកើតមានឡើង នៅពេលដែលការបង្ហាញឆន្ទៈរំលាយនោះ បានធ្វើឡើងចំពោះភាគីទាំងអស់។

→ ថ្ងៃទី១ ខែតុលា អានុភាពនៃការរំលាយកើតមានឡើង។

# 3.1 អានុភាពនៃការរំលាយ (វេវាងភាគី)

- អានុភាពរវាងភាគី

1. រួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា (CC411(1))

→កាតព្វកិច្ចដែលមិនទាន់អនុវត្តត្រូវរលត់ ហើយគ្មានភាពចាំបាច់ត្រូវអនុវត្ត។

2. ករណីយកិច្ចធ្វើបដិទាន (CC411(2))

→ចំពោះកាតព្វកិច្ចដែលអនុវត្តរួចហើយ ត្រូវសងតាវកាលិកដែលបានទទួលវិញ និង មានករណីយកិច្ចធ្វើបដិទានស្ដារភាពដើមនៃកិច្ចសន្យា។


កាតព្វកិច្ចរបស់ X
កាតព្វកិច្ចប្រគល់អង្ករ ១០តោន
X
កាតព្វកិច្ចរបស់ Y
កាតព្វកិច្ចបង់ប្រាក់ថ្លៃទិញ ៥០០០$
Y

# 3.1 អានុភាពនៃការរំលាយ (ទោទភាគី)



- ការអនុវត្តព្រមគ្នានូវករណីយកិច្ចធ្វើបដិទាន (CC411(2))

ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។

# 3.1 អានុភាពនៃការរំលាយ (ទោទភាគី)

ឧទា.

- X បានលក់រថយន្តទៅ Y ក្នុងតម្លៃ ៥000$។
- Y បានបង់ប្រាក់តែ ១000$ តែមិនបានបង់ប្រាក់ថ្លៃទិញដែលនៅសល់ផ្សេងទៀតទេ។
- X បានរំលាយកិច្ចសន្យាលក់ទិញ។

→X មានករណីយកិច្ចសងប្រាក់ ១000$ ហើយ Y មានករណីយកិច្ចប្រគល់រថយន្តវិញ ហើយករណីយកិច្ចទាំង២នេះ គឺត្រូវអនុវត្តព្រមគ្នា។

→ទោះបីជា X ទាមទារឲ្យប្រគល់រថយន្តមុនក៏ដោយ ក៏ Y អាចបដិសេធបានដែរ។

# 3.1 អានុភាពនៃការរំលាយ (វេវាងភាគី)

- ទំហំនៃករណីយកិច្ចធ្វើបដិទាន (CC411(3))
  - អ្នកដែលបានទទួលប្រាក់ ត្រូវសងទាំងការប្រាក់ ដោយគិតចាប់ពីថ្ងៃបានទទួល។
  - អ្នកដែលបានទទួលវត្ថុ ត្រូវសងទាំងផលនៃការប្រើប្រាស់ ដោយគិតចាប់ពីថ្ងៃទទួលបាន។

# 3.1 អានុភាពនៃការរំលាយ (ទោវភាគី)



ឧទា.

- នៅថ្ងៃទី១ ខែសីហា X បានលក់រថយន្តឲ្យ Y ក្នុងតម្លៃ ៥000$ និងបានប្រគល់រថយន្តនោះទៅឲ្យ Y ។
- នៅថ្ងៃទី១0 ខែសីហា Y បានបង់ប្រាក់ ១000$ ឲ្យ X ប៉ុន្តែក្រោយមក ទោះបីជា X ដាស់តឿនក៏ដោយ ក៏ Y មិនព្រមបង់ប្រាក់ដែលនៅសល់ដែរ។
- នៅថ្ងៃទី៣0 ខែកញ្ញា X បានរំលាយកិច្ចសន្យាលក់ទិញ។

→ X ត្រូវបង់ការប្រាក់ ដោយគិតចាប់ពីថ្ងៃទី១0 ខែសីហា បន្ថែមពីលើប្រាក់ ១000$។

យោង. អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ៥% (CC318)

→ Y ត្រូវប្រគល់រថយន្ត ព្រមទាំងថ្លៃឈ្នួលប្រើប្រាស់រថយន្ត ស្របតាមអំឡុងពេលប្រើប្រាស់រថយន្ត ដោយគិតចាប់ពីថ្ងៃទី១ ខែសីហា។

# 3.1 អានុភាពនៃការរំលាយ (ទោទភាគី)



- ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់ (CC412)

ភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក នៅពេលដែលបានរំលាយកិច្ចសន្យា ប៉ុន្តែ ប្រសិនបើមិនអាចប្រគល់កម្មវត្ថុវិញបាន ដោយសារកម្មវត្ថុដែលត្រូវប្រគល់នោះខូចខាត ឬ បាត់បង់ តើត្រូវធ្វើយ៉ាងណា?

# 3.1 អានុភាពនៃការរំលាយ (ទោទភាគី)



- ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់ (CC412)

1. នៅពេលដែលកម្មវត្ថុនោះខូចខាត ឬ បាត់បង់ដោយសារចេតនារបស់អ្នកមានសិទ្ធិរំលាយ ហើយមិនអាចសងវិញបាន

   →មិនអាចរំលាយបាន (សិទ្ធិរំលាយត្រូវរលត់) (CC412(1))

2. នៅពេលដែលកម្មវត្ថុនោះខូចខាត ឬ បាត់បង់ដោយសារកំហុសរបស់អ្នកមានសិទ្ធិរំលាយ ហើយមិនអាចសងវិញបាន

   → អាចរំលាយបាន។ អ្នកមានសិទ្ធិរំលាយត្រូវសងប្រាក់ដែលជាតម្លៃនៃកម្មវត្ថុ ត្រឹមកម្រិតនៃថ្លៃលក់ទិញ (CC412(2))

3. <u>នៅពេលដែលកម្មវត្ថុមិនអាចសងវិញបាន ដោយសារកំហុស ឬ មូលហេតុរបស់ភាគីម្ខាងទៀត</u>

   →អាចរំលាយបាន។ អ្នកមានសិទ្ធិរំលាយមិនមានករណីយកិច្ចសងប្រាក់ដូចមានក្នុងចំណុចទី2 ទេ។

# 3.2 អានុភាពនៃការរំលាយ (ចំពោះតតិយជន)



ការរំលាយកិច្ចសន្យាមិនអាចធ្វើឲ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ (CC411(4))



ចំពោះកិច្ចសន្យាដែលត្រូវបានរំលាយ តើមានឥទ្ធិពលយ៉ាងណាដល់អ្នកមានទំនាក់ទំនងផលប្រយោជន៍?

# 3.2 អានុភាពនៃការរំលាយ (ចំពោះតតិយជន)



- នៅថ្ងៃទី១ ខែសីហា X បានលក់ដី A ក្នុងតម្លៃ ៥០០០០$ ឲ្យទៅ Y និងបានចុះបញ្ជីផ្ទេរ។
- នៅថ្ងៃទី១ ខែតុលា Y បានលក់ដី A ក្នុងតម្លៃ ៥០០០០$ ឲ្យទៅ Z និង បានចុះបញ្ជីផ្ទេរ។
- ទោះបីជា X បានដាស់តឿនក៏ដោយ ក៏ Y នៅតែមិនបង់ថ្លៃទិញដីមួយភាគធំដែរ។
- នៅថ្ងៃទី១ ខែវិច្ឆិកា Y បានរំលាយកិច្ចសន្យាលក់ទិញ។



# 3.2 អានុភាពនៃការរំលាយ (ចំពោះតតិយជន)



- បើសិនជាការទិញលក់ដី A ពី X មក Y ក្លាយជានត្តិភាពដោយសារការរំលាយ នោះផលប្រយោជន៍របស់ Z ដែលបានទិញដី A ដោយការជឿជាក់លើការចុះបញ្ជីរបស់ Y នឹងត្រូវខូចខាតយ៉ាងខ្លាំង ហើយសុវត្ថិភាពជំនួញក៏មានការខូចខាតដែរ។

→ ការរំលាយ មិនអាចធ្វើឲ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់ Z បានឡើយ(CC411(4))

→ អានុភាពនៃការរំលាយ មិនមានចំពោះ Z ទេ។

→ Z អាចតតាំងអំពីលទ្ធកម្មនៃកម្មសិទ្ធិលើដី A ចំពោះ X បាន។



X



Z

# 3.2 អានុភាពនៃការរំលាយ (ចំពោះតតិយជន)



- "ផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជន" ជាអ្វី?

→ ដោយសារការបកស្រាយនេះមិនមានកំណត់ក្នុងច្បាប់ ហេតុនេះ ត្រូវពឹងផ្អែកលើយុត្តិសាស្ត្រតុលាការ។

- តើករណីណាខ្លះ ដែលយើងអាចនិយាយថា Z មានផលប្រយោជន៍ត្រឹមត្រូវ ?
  - នៅពេលដែល Z មិនទាន់ចុះបញ្ជីដី A រួចរាល់ តើករណីនេះយ៉ាងម៉េចដែរ?
  - នៅពេលដែល Z បានដឹងថា Y មិនមានទ្រព្យសម្បត្តិ ហើយមិនអាចបង់ប្រាក់ថ្លៃទិញបាន តើករណីនេះយ៉ាងម៉េចដែរ?
  - នៅពេលដែល Y បានប្រាប់ Z ថា ចង់លក់ដីនោះមុនពេល X រំលាយកិច្ចសន្យា ហើយឃុបឃិតគ្នាទិញយកដីនោះក្នុងតម្លៃក្រោមទីផ្សារខ្លាំង តើករណីនេះយ៉ាងម៉េចដែរ?

# 4.អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា



"អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទាន មានអំឡុងពេល៥ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច" (CC413)។

- ចំណុចនៃការគណនាអំឡុងពេល ： ពេលដែលមិនបានអនុវត្តកាតព្វកិច្ច →នៅពេលអលទ្ធភាពក្នុងការអនុវត្ត នៅពេលយឺតយ៉ាវក្នុងការអនុវត្ត
- អំឡុងពេល ： ៥ឆ្នាំ

យោង.

・អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង (CC406)។

・អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ មានអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិនោះបាន (CC481, 482)។

# 4.អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា



មធ្យោបាយសង្គ្រោះផ្សេងៗនៃការមិនអនុវត្តកាតព្វកិច្ច និងអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់

1. សិទ្ធិទាមទារឲ្យអនុវត្ត
   → ៥ឆ្នាំ គិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិបាន
2. សិទ្ធិទាមទារសំណងនៃការខូចខាត
   → ៥ឆ្នាំ គិតចាប់ពីពេលដែលការខូចខាតបានកើតឡើង
3. សិទ្ធិរំលាយ
   → ៥ឆ្នាំ គិតចាប់ពីពេលមិនអនុវត្តកាតព្វកិច្ច

# 5. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង



ក្រៅពីការរំលាយដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច ក៏មានមូលហេតុដែលស្រដៀងទៅនឹងមូលហេតុនេះដែរ គឺការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង។

1. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា (CC414(1))

   គឺជាការផ្តល់ឲ្យភាគីម្ខាង ឬ ភាគីទាំងសងខាងនូវសិទ្ធិរំលាយ ក្នុងករណីជាក់លាក់មួយដោយផ្អែកលើកិច្ចសន្យា (ទោះបីជាគ្មានការមិនអនុវត្តកាតព្វកិច្ចក៏ដោយ) ។

   ឧទា. គូភាគីទាំងសងខាងអាចរំលាយកិច្ចសន្យាបានភ្លាម នៅពេលភាគីម្ខាងទៀតទទួលការចាត់ចែងអំពីពន្ធតឹងទារ។

2. ការរំលាយដោយការព្រមព្រៀង (CC414(2))

   គឺជាការព្រមព្រៀងរំលាយកិច្ចសន្យាដោយគូភាគី។

# 5. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង



1. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា (CC414(1))

គឺជាការផ្តល់ឲ្យភាគីម្ខាង ឬ ភាគីទាំងសងខាងនូវសិទ្ធិរំលាយ ក្នុងករណីជាក់លាក់មួយដោយផ្អែកលើកិច្ចសន្យា។

→ចំណុចដែលអ្នកមានសិទ្ធិរំលាយអនុវត្តសិទ្ធិរំលាយដោយបង្ហាញឆន្ទៈតែម្ខាង គឺជាចំណុចដូចគ្នានឹងការរំលាយដោយសារការមិនអនុវត្តកាតព្វកិច្ច។

→បញ្ញត្តិស្តីពីវិធីអនុវត្តសិទ្ធិរំលាយ (CC409,410) និង អានុភាពនៃការរំលាយ (CC411,412) នឹងត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែមានការព្រមព្រៀងពិសេស។

# 5. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង



2. ការរំលាយដោយការព្រមព្រៀង (CC414(2))

គឺជាការព្រមព្រៀងរំលាយកិច្ចសន្យាដោយគូភាគី

→ដោយសារតែការរំលាយធ្វើឡើងតាមរយៈកិច្ចសន្យា ហេតុនេះខ្លឹមសារនោះត្រូវប្រគល់ឲ្យគូភាគីជាអ្នកសម្រេច។

→" ប៉ុន្តែ មិនអាចធ្វើឲ្យខូចផលប្រយោជន៍របស់តតិយជនទេ។"

※អានុភាពនៃការរំលាយ(ចំពោះតតិយជន)

"ផលប្រយោជន៍របស់តតិយជន" នៃ CC414(2) មានខ្លឹមសារទូលាយជាង "ផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជន" នៃ CC411(4)។ ការរំលាយដោយការព្រមព្រៀង គឺជាការរំលាយកិច្ចសន្យាដោយផ្អែកតាមតែស្ថានភាពរបស់គូភាគី ទោះបីជាគ្មានការមិនអនុវត្តកាតព្វកិច្ចក៏ដោយ ដូច្នេះ ជាទូទៅការរំលាយកិច្ចសន្យាបែបនេះមិនត្រូវធ្វើឲ្យប៉ះពាល់ដល់បុគ្គលដទៃឡើយ។

# 5. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង



- ថ្ងៃទី១ ខែសីហា X បានលក់ដីA ក្នុងតម្លៃ ៥០០០០$ ទៅឲ្យ Y ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ្យ Y រួចរាល់ហើយ។
- ថ្ងៃទី១ ខែតុលា Y បានលក់ដីA ក្នុងតម្លៃ ៥០០០០$ ទៅឲ្យ Z ប៉ុន្តែមិនទាន់បានចុះបញ្ជី។
- ថ្ងៃទី១ ខែវិច្ឆិកា X និង Y បានព្រមព្រៀងគ្នារំលាយកិច្ចសន្យាលក់ទិញ។



# 5. ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង



អានុភាពនៃការផ្ទេរកម្មសិទ្ធិលើដីពី Y ទៅ Z មិនកើតឡើងទេ (CC135) ដោយសារតែមិនទាន់ចុះបញ្ជីផ្ទេរកម្មសិទ្ធិ ហេតុនេះ Z មិនទាន់បានធ្វើលទ្ធកម្មនៃកម្មសិទ្ធិជាស្ថាពរនៅឡើយ។

→ ទោះបីជាមានករណីបែបនេះក៏ដោយ ក៏ការរំលាយដោយការព្រមព្រៀងមិនអាចធ្វើឲ្យខូចប្រយោជន៍របស់តតិយជន Z បានឡើយ ។

→ អានុភាពនៃការរំលាយតាមការព្រមព្រៀងមិនមានចំពោះ Z ទេ។



# សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!

តើមានសំណួរដែរឬទេ?



# ការពន្យល់អំពីទ្រឹស្ដីនៃអានុភាពនៃការរំលាយ(ជំនួយស្មារតី)

58

- គំនិតដែលទទួលស្គាល់អានុភាពប្រតិសកម្ម

→ គ្មានកិច្ចសន្យាតាំងពីដំបូង។

  - កាតព្វកិច្ចដែលមិនទាន់អនុវត្ត ត្រូវរលត់។
  - កាតព្វកិច្ចដែលបានអនុវត្តរួចរាល់ បានក្លាយជាការធ្វើលទ្ធកម្មដោយគ្មានមូលហេតុតាមផ្លូវច្បាប់ ហើយត្រូវមានករណីយកិច្ចសងវិញ ដោយសេចក្ដីចម្រើនដោយឥតហេតុ (អានុភាពនៃការផ្ទេរកម្មសិទ្ធិមិនបានកើតឡើងវិញ។)។

- គំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម

→ កាតព្វកិច្ចធ្វើបដិទានមកស្ថានភាពដើមវិញ នឹងកើតមានឡើងនៅពេលរំលាយ។

  - កាតព្វកិច្ចដែលមិនទាន់អនុវត្ត នឹងកើតមានសិទ្ធិបដិសេធក្នុងការអនុវត្ត។
  - កាតព្វកិច្ចដែលបានអនុវត្តរួចរាល់ នឹងកើតមានករណីយកិច្ចឲ្យសងវិញ។

ឧទា.

- X បានចុះកិច្ចសន្យាលក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួន ទៅឲ្យ Y។
- X បានប្រគល់ដី និង ចុះបញ្ជីផ្ទេរឲ្យទៅ Y។
- Y មិនបានបង់ប្រាក់ថ្លៃទិញដីឲ្យមក X ទេ។
- X បានរំលាយកិច្ចសន្យាលក់ទិញ។



# គំនិតទទួលស្គាល់អានុភាពប្រតិសកម្ម



- កាតព្វកិច្ចបង់ប្រាក់ថ្លៃទិញរបស់ Y នឹងរលត់។
- កម្មសិទ្ធិនៃដីនឹងត្រឡប់ទៅ X វិញតាមអានុភាពប្រតិសកម្ម ហើយមិនមានការផ្ទេរកម្មសិទ្ធិដីនោះទាល់តែសោះ។
  - →Y ត្រូវសងដីឲ្យ X វិញ ហើយត្រូវធ្វើនីតិវិធីចុះបញ្ជីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃដីនោះ។



# គំនិតមិនទទួលស្គាល់អានុភាពប្រតិសកម្ម



- Y អាចបដិសេធការអនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្លៃទិញបាន។
- Y មានករណីយកិច្ចត្រូវសងទៅ X វិញនូវកម្មសិទ្ធិនៃដី។

→Y ត្រូវសងដីទៅឲ្យ X ហើយត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិពី Y ទៅ X។

